សមាគមយុវជនខ្មែរ

Khmer Youth Association

#135 A, Group 33, St 259, Sangkat Teok La-ark I, Khan Toul Kork
Phnom Penh Cambodia.

Tel/Fax:855-23-884 306
E-mail:admin@kya-cambodia.org
CCC.Box:275

Mobile Phone: 855 17 788 955
website:www.kya-cambodia.org


# ដំណឹងជ្រើសរើសបុគ្គលិក

សមាគមយុវជនខ្មែរជាអង្គការមិនមែនរដ្ឋាភិបាល ធ្វើការជាមួយយុវជន ដើម្បីយុវជន និងលើកកម្ពស់យុវជនឲ្យចូលរួមក្នុងការអភិវឌ្ឍសង្គម ហើយមានស្នាក់ការកណ្តាលនៅទីក្រុងភ្នំពេញ និងសាខាតាមខេត្តចំនួន៨រួមមានៈ កំពង់ចាម បាត់ដំបង បន្ទាយមានជ័យ តាកែវ ព្រៃវែង សៀមរាប ស្វាយរៀង និងកំពង់ឆ្នាំង ។ សមាគមយុវជនខ្មែរត្រូវការជ្រើសរើស**ប្រធានសាខាចំនួន០១**នាក់ធ្វើការនូវសមាគមយុវជនខ្មែរ *សាខាខេត្តសៀមរាប*។

## ភារៈការទទួលខុសត្រូវ

*១. រៀបចំគ្រប់គ្រង បែងចែក និង ត្រួតពិនិត្យការងារគម្រោង*

- សម្របសម្រួលការរៀបចំផែនការសកម្មភាពផែនការតាមដាន - ត្រួតពិនិត្យរាល់ការរីកចំរើនគ្រប់គម្រោងទាំងអស់នៅក្នុងខេត្តរបស់ខ្លួន
- បំពេញផែនការការងារ ការតាមដាន-ត្រួពិនិត្យ ដោយធានាប្រសិទ្ធិភាព គុណភាព និងតម្លាភាព
- សរសេររបាយការណ៍លទ្ធផលការងារគម្រោងប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ដែលស្ថិត នៅក្រោមការទទួលខុសត្រូវរបស់ខ្លួនមកកាន់ប្រធានផ្នែកនៅស្នាក់ការកណ្តាល និងដំកល់ទុកនៅក្នុងខេត្តរបស់ខ្លួន
- រៀបចំការងារគ្រប់គ្រងបុគ្គលិកតាមរយៈ ការប្រជុំជាមួយបុគ្គលិក គ្រូបង្គោល សកម្មជនបណ្តាញក្នុងខេត្តរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាចែករំលែកព័តមាន និងបណ្តុះបណ្តាលសមត្ថភាពរបស់ខ្លួន ។

*២. រៀបចំគ្រប់គ្រងបែងចែក និងត្រួតពិនិត្យការងាររដ្ឋបាលក្នុងការិយាល័យ*

- ការថែរក្សាសណ្តាប់ធ្នាប់ អនាម័យ បរិស្ថាន សោភ័ណភាពនៅក្នុងការិយាល័យ
- ការគ្រប់គ្រង និងបែងចែកការងារសម្រាប់អ្នកស្នាក់នៅក្នុងការិយាល័យ
- ការរៀបចំផ្សព្វផ្សាយទទួលពាក្យសុំ-ថវិការ ការចុះបញ្ជី ការធ្វើរបាយការណ៍ និងថែរក្សាតម្កល់ពាក្យសុំចូលជាសមាជិករបស់សមាជិក
- ត្រួតពិនិត្យ គ្រប់គ្រងនិងថែរក្សាសម្ភារៈប្រើប្រាស់នៅក្នុងផ្នែករបស់ខ្លួន
- ត្រួតពិនិត្យកំណត់ហេតុ ការចុះសារពើពន្ធថ្នាក់ខេត្ត
- ត្រួតពិនិត្យរបាយការណ៍ការងាររដ្ឋបាលប្រចាំខែប្រចាមត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំនៅក្នុងខេត្តរបស់ខ្លួនមុននឹងផ្ញើមកស្នាក់ការកណ្តាល ។

*៣.រៀបចំគ្រប់គ្រង និងត្រួតពិនិត្យការងារ ហិរញ្ញវត្ថុ*

*៤.ការងារទំនាក់ទំនងខាងក្រៅនិងផ្សេងៗ*

- តាមដាន និងសិក្សាស្រាវជ្រាវអំពីបច្ចុប្បន្នភាពនៃច្បាប់គោលនយោបាយរបស់រដ្ឋាភិបាលនិងស្ថាប័នពាក់ព័ន្ធ
- ចូលរួមប្រជុំ តស៊ូមតិ សិក្ខាសាលា វគ្គបណ្តុះបណ្តាលដើម្បីពង្រឹងទំនាក់ទំនងជាមួយនិងស្ថាប័នពាក់ព័ន្ធ នៅក្នុងខេត្តនិងម្ចាស់មូនិធិ អង្គការក្នុងស្រុកនិងអង្គការអន្តរជាតិនានា។

## លក្ខខ័ណ្ឌនៃការជ្រើសរើស

- មានចំណាប់អាម្មរណ៏ក្នុងការងារសង្គម និងមានទំនាក់ទំនងល្អ
- មានសញ្ញាបត្របរិញ្ញាបត្រផ្នែកគ្រប់គ្រង ឬច្បាប់
- មានបទពិសោធន៏ធ្វើការងារទាក់ទងនឹងការគ្រប់គ្រងយ៉ាងតិចបីឆ្នាំ
- មានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ
- ចេះភាសាអង់គ្លេសសរសេរ និងនិយាយបានល្អ
- ចេះប្រើប្រាស់កំព្យូទ័រ( word Excel and other Program )
- មានគំនិតច្នៃប្រឌិត និងចេះធ្វើការងារជាក្រុម ។

បើសិនជាបេក្ខជន បេក្ខនារីមានចំណាប់អារម្មណ៏ សូមសរសេរប្រវត្តិរូបផ្ទាល់ខ្លួន និងលិខិតចំណាប់អារម្មណ៏ មកសមាគមយុវជនខ្មែរសាខាខេត្តសៀមរាប ដែលមានអាស័យដ្ឋាន ផ្ទះ ០៦៩៣ ភូមិវត្តបូណ៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ឬស្នាក់ការកណ្តាលរាជធានីភ្នំពេញ ផ្ទះលេខ១៣៥អា ផ្លូវ២៥៩ សង្កាត់ទឹកល្អក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ឬតាមទូរស័ព្ទ

- ០១៧ ៣៦៨ ៧៦៧/០១៥ ៧១៤ ៥៤៥
- ០១២ ៣២៤ ៦៩១/០២៣ ៨៨៤ ៣០៦
- ឬតាមអ៊ីម៉ែល admin@kya-cambodia.org ។

បេក្ខនារីត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យ!

ការដាក់ពាក្យផុតកំណត់នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១២ វេលាម៉ោង ១៧: ០០ រសៀល ។